# ព្រះរាជក្រម

នស/រកម/០១១៧/០០២

**រដ្ឋសភា**
ចូល
លេខ ...
ថ្ងៃទី ... ឆ្នាំ ... ម៉ោង ...
បញ្ជូនទៅ ...

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា៨ មាត្រា៤០ មាត្រា៤១ មាត្រា៤៧ មាត្រា៤៨ មាត្រា៧៥ មាត្រា៧៧ មាត្រា៨២ និងមាត្រា៩០ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០១៥ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៤ ខែមករា ឆ្នាំ២០១៧ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់
# ស្តីពី
# វិសោធនកម្មមាត្រា ៨ មាត្រា ៤០ មាត្រា ៤១ មាត្រា ៤៧ មាត្រា ៤៨ មាត្រា ៧៥ មាត្រា ៧៧ មាត្រា ៨២ និងមាត្រា ៩០ នៃច្បាប់ស្តីពី ចរាចរណ៍ផ្លូវគោក

ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រម

លេខ នស/រកម/០១១៥/០០១

ចុះថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០១៥

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រាមួយ.–**

មាត្រា ៨ មាត្រា ៤០ មាត្រា ៤១ មាត្រា ៤៧ មាត្រា ៤៨ មាត្រា ៧៥ មាត្រា ៧៧ មាត្រា ៨២ និងមាត្រា ៩០ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី ៩ ខែ មករា ឆ្នាំ២០១៥ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

**មាត្រា ៨.–ថ្មី**

គ្រប់អ្នកបើកបរយានយន្តគ្រប់ប្រភេទ ត្រូវអនុវត្តនូវវិធានការដូចតទៅ៖

១- ត្រូវមានបណ្ណបើកបរចំពោះអ្នកបើកបរយានយន្តដូចខាងក្រោម៖

-រថយន្តគ្រប់ប្រភេទ

-ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក និងត្រីចក្រយានយន្ត

-យានយន្តដែលមានទំហំស៊ីឡាំងលើសពី ១២៥ (មួយរយម្ភៃប្រាំ) សង់ទីម៉ែត្រគូប ឡើងទៅ ឬមានថាមពលអគ្គិសនីលើសពី ១១ (ដប់មួយ) គីឡូវ៉ាត់ ។ ចំពោះយានយន្តដែលមានទំហំស៊ីឡាំងចាប់ពី ១២៥ (មួយរយម្ភៃប្រាំ) សង់ទីម៉ែត្រគូបចុះក្រោម ឬមានថាមពលអគ្គិសនីចាប់ពី ១១ (ដប់មួយ) គីឡូវ៉ាត់ចុះក្រោម អ្នកបើកបរមិនតម្រូវឲ្យមានបណ្ណបើកបរឡើយ ប៉ុន្តែត្រូវមានអាយុយ៉ាងតិច ១៥ (ដប់ប្រាំ) ឆ្នាំឡើងទៅ ដោយមានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬឯកសារបញ្ជាក់អត្តសញ្ញាណណាមួយ ។

២- នៅពេលបើកបរយានជំនិះ អ្នកបើកបរត្រូវមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ចហើយស្ថិតក្នុងស្ថានភាពដែលអាចធ្វើសកម្មភាពបើកបរបានយ៉ាងស្រួល និងឆាប់រហ័ស ជាពិសេសលទ្ធភាពនៃការធ្វើចលនាមិនត្រូវឲ្យមានការរំខានឡើយ ។

៣- ហាមធ្វើឲ្យរំខានដល់អ្នករស់នៅជាប់តាមដងផ្លូវ និងអ្នកប្រើប្រាស់ផ្លូវ ។

៤- ហាមពិសាគ្រឿងស្រវឹងដែលបណ្តាលឲ្យមានអត្រាជាតិអាល់កុលចាប់ពី ០,២៥ (សូន្យក្បៀសម្ភៃប្រាំ) មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០,៥០ (សូន្យក្បៀសហាសិប) ក្រាមក្នុងមួយលីត្រឈាមឡើងទៅ ។

៥- ហាមបើកបរយានជំនិះដែលមានកង់ច្រវាក់ដែកផ្ទាល់លើទ្រូងផ្លូវ ។ យានជំនិះប្រភេទនេះ ត្រូវដឹកតាមយានជំនិះដែលមានប្រភេទកង់កៅស៊ូ ។

៦- ហាមប្រើទូរស័ព្ទនៅពេលកំពុងបើកបរយានជំនិះដោយគ្មានឧបករណ៍សំឡេងភ្ជាប់ទំនាក់ទំនង ។

៧- ហាមផ្ទុកអ្នកដំណើរ ទំនិញ ឬវត្ថុផ្សេងៗដែលនាំឲ្យបាំងភ្នែកអ្នកបើកបរ ។

៨- ទោចក្រយានយន្តអាចផ្ទុកមនុស្សពីរនាក់និងអាចបន្ថែមបានកុមារមួយនាក់ ។ អ្នកបើកបរទោចក្រយានយន្តនិងអ្នករួមដំណើរ ព្រមទាំងកុមារដែលមានអាយុចាប់ពី ៣(បី)ឆ្នាំ ឡើងទៅ

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ត្រូវពាក់មួកសុវត្ថិភាពឲ្យបានត្រឹមត្រូវ ។ អ្នកបើកបរត្រីចក្រយានយន្ត និងអ្នកបើកបរទោចក្រយានយន្តសណ្តោងរ៉ឺម៉ក ត្រូវពាក់មួកសុវត្ថិភាពឲ្យបានត្រឹមត្រូវ ។

៩- នៅក្នុងទីប្រជុំជនអ្នកបើកបរ និងអ្នករួមដំណើរជិះកៅអីមុខនៃរថយន្ត ត្រូវពាក់ខ្សែក្រវាត់សុវត្ថិភាព ។

១០-នៅក្រៅទីប្រជុំជនអ្នកបើកបរ និងអ្នករួមដំណើរទាំងអស់តាមរថយន្ត ត្រូវពាក់ខ្សែក្រវាត់សុវត្ថិភាព ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៩០ ថ្មី នៃច្បាប់នេះ ។

១១-កុមារអាយុតិចជាង ១០(ដប់) ខែ ត្រូវដាក់ក្នុងកៅអីសម្រាប់កុមារដេក និងមានខ្សែក្រវាត់សុវត្ថិភាពចងផ្អែកកៅអីនេះឲ្យជាប់ទៅនឹងកៅអីក្រោយនៃរថយន្ត ។

១២-កុមារមានអាយុចាប់ពី ១០ (ដប់ )ខែ ទៅក្រោម ៥(ប្រាំ) ឆ្នាំ ត្រូវអង្គុយក្នុងកៅអីសម្រាប់កុមារដែលមានខ្សែក្រវាត់សុវត្ថិភាពចងផ្អែកកៅអីនេះឲ្យជាប់ទៅនឹងកៅអីក្រោយនៃរថយន្ត ។

១៣- ហាមកុមារអាយុក្រោម ១០ (ដប់) ឆ្នាំ អង្គុយនៅកៅអីមុខនៃរថយន្ត ។

## មាត្រា ៤០.-ថ្មី

បណ្ណបើកបរជាតិសម្រាប់បើកបរយានយន្តក្នុងព្រះរាជាណាចក្រកម្ពុជា មាន ៥ (ប្រាំ) ប្រភេទដូចខាងក្រោម៖

**ប្រភេទក** : ទោចក្រយានយន្ត ដែលមានទំហំស៊ីឡាំងលើសពី ១២៥ (មួយរយម្ភៃប្រាំ) សង់ទីម៉ែត្រគូប ឬមានថាមពលអគ្គិសនីលើសពី ១១ (ដប់មួយ) គីឡូវ៉ាត់ ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក និងត្រីចក្រយានយន្ត ។

**ប្រភេទខ** : រថយន្តដឹកអ្នកដំណើរមិនលើសពី ៩ (ប្រាំបួន) នាក់ ដោយគិតទាំងអ្នកបើកបរ

- រថយន្តដឹកទំនិញដែលមានទម្ងន់សរុបអតិបរមាមិនលើសពី ៣,៥ (បីក្បៀសប្រាំ) តោន
- រថយន្តក្នុងប្រភេទ **ខ** នេះ អាចសណ្តោងរ៉ឺម៉កដែលមានទម្ងន់សរុបអតិបរមាមិនលើសពី ០,៧៥ (សូន្យក្បៀសចិតសិបប្រាំ) តោន ។

**ប្រភេទគ** : រថយន្តដឹកទំនិញដែលមានទម្ងន់សរុបអតិបរមាលើសពី ៣,៥ (បីក្បៀសប្រាំ) តោន និងអាចសណ្តោងរ៉ឺម៉កដែលមានទម្ងន់សរុបអតិបរមាមិនលើសពី ០,៧៥ (សូន្យក្បៀសចិតសិបប្រាំ) តោន ។

**ប្រភេទឃ** : រថយន្តដឹកអ្នកដំណើរ៖

**ឃ១**: រថយន្តដឹកអ្នកដំណើរចាប់ពី ១០ (ដប់) នាក់ ដល់ ២០(ម្ភៃ) នាក់ ដោយគិតទាំងអ្នកបើកបរ និងអាចមានសណ្តោងរ៉ឺម៉កដែលមានទម្ងន់សរុបអតិបរមាមិនលើសពី ០,៧៥ (សូន្យក្បៀសចិតសិបប្រាំ) តោន ។

**ឃ២**: រថយន្តដឹកអ្នកដំណើរលើសពី ២០ (ម្ភៃ) នាក់ ដោយគិតទាំងអ្នកបើកបរ និងអាចមានសណ្តោងរ៉ឺម៉កដែលមានទម្ងន់សរុបអតិបរមាមិនលើសពី ០,៧៥ (សូន្យក្បៀសចិតសិបប្រាំ) តោន ។